៤- អាជ្ញាធរមូលដ្ឋាន ភូមិ ឃុំ ស្រុក ត្រូវជួយផ្សព្វផ្សាយ និងចូលរួមបញ្ឈប់ជាបន្ទាន់នូវការចូលកាប់ទន្ទ្រានឈូសឆាយដីព្រៃ ដាំដំណាំ សាងសង់ផ្ទះ ខ្ទម រោង ធ្វើរបងហ៊ុំព័ទ្ធ ក្នុងភូមិសាស្ត្រខេត្តក្រចេះ និងត្រូវបញ្ឈប់ជាបន្ទាន់នូវការចូលរស់នៅ កាន់កាប់ ដោយត្រូវរុះរើដោយវិធានការរដ្ឋបាល ឬដោយការស្ម័គ្រចិត្ត ។

៥- ក្នុងករណីមិនអនុវត្តតាមខ្លឹមសារសេចក្ដីជូនដំណឹងខាងលើនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត និងស្រុកពាក់ព័ន្ធនឹងចាត់វិធានការអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន។

ទទួលបានសេចក្ដីជូនដំណឹងនេះ រដ្ឋបាលខេត្តក្រចេះ សង្ឃឹមយ៉ាងមុតមាំថា អាជ្ញាធរមូលដ្ឋានភូមិ ឃុំ ស្រុកពាក់ព័ន្ធ ផ្នែកជំនាញ សាធារណជន និងប្រជាពលរដ្ឋ ព្រមទាំងអ្នកពាក់ព័ន្ធដែលកំពុងរស់នៅ និងកាន់កាប់ដីព្រៃខុសច្បាប់នៅក្នុងតំបន់ការពារធម្មជាតិ នឹងចូលរួមអនុវត្តតាមសេចក្ដីជូនដំណឹងនេះ និងចូលរួមអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធឱ្យមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។/.

**អភិបាលខេត្ត**

**វ៉ា ថន**

**ចម្លងជូន៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត

**«ដើម្បីគោរពជូនជ្រាប»**

- សាលាដំបូងខេត្ត
- អយ្យការអមសាលាដំបូងខេត្តក្រចេះ
- ស្នងការដ្ឋាននគរបាលខេត្តក្រចេះ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តក្រចេះ
- បញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករងក្រចេះ
- មន្ទីរ អង្គភាពពាក់ព័ន្ធ
- រដ្ឋបាលក្រុង ស្រុក
- រដ្ឋបាលឃុំ សង្កាត់

**«ដើម្បីជ្រាប និងសហការអនុវត្ត»**

- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តក្រចេះ**

លេខ ១៩៧ / ស.ជ.រ.ល / ២៤

ថ្ងៃចន្ទ ១៣ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស២៥៦៧

ក្រចេះ ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

## ស្តីពី

## វិធានការទប់ស្កាត់ និងដកហូតដីព្រៃ ដែលបានកាប់ទន្ទ្រានយកធ្វើជាកម្មសិទ្ធិ ខុសច្បាប់ក្នុងតំបន់ការពារធម្មជាតិ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តក្រចេះ

**យោង:** - លិខិតលេខ ១១២៧/០៣២៤ សជណ.បស្ក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ របស់ក្រសួងបរិស្ថាន ស្តីពីវិធានការទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់គាស់ រុករាន ឆ្ការដុត ឬឈូសឆាយដីព្រៃក្នុងតំបន់ការពារធម្មជាតិធ្វើជាកម្មសិទ្ធិ។

- ស្មារតីកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត នៅថ្ងៃទី៤ ខែមេសា ឆ្នាំ ២០២៤ ស្តីពីការទប់ស្កាត់ការកាប់ទន្ទ្រានដីព្រៃយកជាកម្មសិទ្ធិដោយខុសច្បាប់ក្នុងតំបន់ការពារធម្មជាតិស្ថិតក្នុងភូមិសាស្ត្រខេត្តក្រចេះ។

រដ្ឋបាលខេត្តក្រចេះ សូមជម្រាបជូនសាធារណជន និងបងប្អូនប្រជាពលរដ្ឋ ជ្រាបថា រដ្ឋបាលខេត្តបានសង្កេតឃើញមានបងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងមកពីបណ្តាខេត្តផ្សេងៗ បានចូលទៅកាប់ទន្ទ្រានដីព្រៃដោយខុសច្បាប់ក្នុងតំបន់ការពារធម្មជាតិ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តក្រចេះ ចាប់តាំងពីឆ្នាំ២០១៩មក ដែលសកម្មភាពនេះជាការបំផ្លិចបំផ្លាញធនធានធម្មជាតិយ៉ាងធ្ងន់ធ្ងរ ទោះបីជារដ្ឋបាលខេត្ត ផ្នែកជំនាញ និងអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបជាបន្តបន្ទាប់យ៉ាងណាក្តី ក៏នៅមានប្រជាពលរដ្ឋបន្តការចូលកាប់គាស់ រុករាន ទន្ទ្រាន ដាំដំណាំ សង់លំនៅដ្ឋាន ធ្វើរបងហ៊ុំព័ទ្ធ និងទាមទារស្នើសុំឱ្យអាជ្ញាធរវាស់វែង ដើម្បីបានប្រើប្រាស់អាស្រ័យផលស្របច្បាប់ថែមទៀត។

ក្នុងន័យនេះ ដើម្បីបន្តពង្រឹងប្រសិទ្ធភាពលើការគ្រប់ដីរដ្ឋ និងធនធានព្រៃឈើនៅតាមតំបន់ការពារធនធានធម្មជាតិក្នុងភូមិសាស្ត្រខេត្តក្រចេះ រដ្ឋបាលខេត្តក្រចេះ សូមដាក់ចេញនូវវិធានការ ដូចខាងក្រោម៖

១- មោឃភាពចោលនូវរាល់លិខិតលក់-ទិញ ឬលិខិតបញ្ជាក់កាន់កាប់ដីព្រៃខុសច្បាប់ នៅក្នុងតំបន់ការពារធម្មជាតិ ។

២- ដកហូតយកមកជាសម្បត្តិរដ្ឋវិញ នូវរាល់ដីព្រៃ ដែលបានកាប់គាស់ រុករាន ទន្ទ្រាន ដាំដំណាំ សង់លំនៅដ្ឋាន ធ្វើរបងហ៊ុំព័ទ្ធ ក្នុងតំបន់ការពារធម្មជាតិ ។

៣- ការកាប់កាស់ រុករានដីព្រៃ ដុតព្រៃ សង់ផ្ទះ សង់តូប រោង ធ្វើរបងហ៊ុំព័ទ្ធ និងដាំដំណាំដើម្បីយកដីធ្វើជាកម្មសិទ្ធិក្នុងតំបន់ការពារធម្មជាតិ គឺជាបទល្មើសធនធានធម្មជាតិ ដែលមានចែងក្នុងមាត្រា៦១ និងមាត្រា៦២ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។